# សន្ទរកថា ឯកឧត្តម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី
# និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
# ក្នុងពិធីអបអរសាទរ " ទិវាឆ្នាំអន្តរជាតិនៃជីវៈចម្រុះ នៅប្រទេសកម្ពុជា "

## ខេត្តសៀមរាប ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១០

- សូមក្រាបថ្វាយបង្គំព្រះថេរា នុថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ
- **ឯកឧត្តមបណ្ឌិត មុំ ម៉ារ៉េត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន
- **ឯកឧត្តម ស៊ូ ភិរិន** អភិបាលនៃគណៈអភិបាលខេត្តសៀមរាប
- **លោក អាល់មេត យ៉ុឡាស (Ahmed Djoghlaf)** អគ្គលេខាធិការ នៃលេខាធិការដ្ឋានអនុសញ្ញាសហប្រជាជាតិស្តីពីជីវចម្រុះ ប្រចាំនៅទីក្រុង ម៉ុងរ៉េអាល់ ប្រទេសកាណាដា
- ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ជាទីមេត្រី

១. ថ្ងៃនេះ ជាថ្ងៃនក្ខត្តឫក្សប្រកបដោយក្តីសោមនស្សរីករាយ និងរំភើបក្រៃលែង ដោយខ្ញុំព្រះករុណាខ្ញុំ មានកិត្តិយសបានមកចូលរួមក្នុងពិធីអបអរសាទរ " **ទិវាឆ្នាំអន្តរជាតិនៃជីវៈចម្រុះ នៅប្រទេសកម្ពុជា** " ដ៏មានសារៈសំខាន់នៅពេលនេះ ។ ក្នុងនាមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការអបអរសាទរដល់ការរៀបចំទិវាឆ្នាំអន្តរជាតិនៃជីវៈចម្រុះ ២០១០ និងកោតសរសើរយ៉ាងជ្រាលជ្រៅដល់ថ្នាក់ដឹកនាំ-មន្ត្រីរាជការ នៃក្រសួងបរិស្ថាន ជាពិសេសឯកឧត្តម **មុំ ម៉ារ៉េត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងបរិស្ថាន ដែលបានដឹកនាំ និងរៀបចំវេទិកានេះ លើទឹកដីអង្គរដ៏បវរនៃយើង ហើយក៏ជាការគូសបញ្ជាក់ពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ក្នុងការរួមចំណែកកាត់បន្ថយ និងទប់ស្កាត់នូវការបាត់បង់ជីវៈចម្រុះនៅលើសកលលោក និយាយដោយឡែកគឺនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ខ្ញុំសូមឧទ្ទិសឱ្យអត្ថន័យនៃឆ្នាំអន្តរជាតិជីវចម្រុះ២០១០ នាថ្ងៃនេះបានជ្រួតជ្រាប និងបង្កើនការយល់ដឹងដល់ប្រជាជនកម្ពុជា ក្នុងការរួមចំណែកការពារបរិស្ថាន និងធនធានធម្មជាតិដ៏ស្រស់បំព្រងរបស់យើង ដោយរក្សាឱ្យបាននូវនិរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ី និងទាក់ទាញភ្ញៀវទេសចរណ៍ ក្នុងបុព្វហេតុរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

២. ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងមន្ត្រីរាជការក្រោមឱវាទក្រសួងបរិស្ថាន និងក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ-អន្តរជាតិ នានាដែលបានបំពេញភារកិច្ចយ៉ាងល្អប្រពៃ និងសម្រេចបាននូវជោគជ័យ និងសមិទ្ធផលដ៏ធំធេងក្នុងការគ្រប់គ្រង ថែរក្សាការពារ និងអភិរក្សធនធានជីវៈចម្រុះដ៏សម្បូរបែបនៅក្នុងប្រទេសកម្ពុជា ។ នេះជាការងារមួយដ៏មានតម្លៃដើរស្របគ្នានឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៤នៃរដ្ឋសភា ជាពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាល ដែលបានបញ្ជាក់ពីឆន្ទៈរបស់ប្រមុខរាជរដ្ឋាភិបាល ក្នុងការរក្សាឱ្យបាននូវការអភិវឌ្ឍមួយដែលត្រូវតែមានតុល្យភាព នឹងការអភិរក្សគ្រប់គ្រង និងថែរក្សាបរិស្ថាន និងធនធានធម្មជាតិ ។

៣. កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានជីវៈចម្រុះ ពុំមែនជាការងាយស្រួលឡើយ ហើយកិច្ចការនេះក៏មិនអាចសម្រេចបានក្នុងរយៈពេលខ្លីនោះដែរ វាទាមទារនូវពេលវេលា និងឆន្ទៈនយោបាយដ៏មុះមុតដើម្បីអនុវត្តន៍ ហើយជាការពិតការអនុវត្តជាក់ស្តែងវាមានលក្ខណៈលំបាក និងស្មុគ្រស្មាញយ៉ាងខ្លាំងដោយមានការពាក់ព័ន្ធដោយផ្ទាល់ និងដោយប្រយោល ជាមួយនឹងការអភិវឌ្ឍទៅតាមវិស័យ ព្រោះថាជីវៈចម្រុះ ជាប្រភពធនធានដ៏វិសេសវិសាលសម្រាប់ការអភិវឌ្ឍផង និងជួយទ្រទ្រង់ដល់លំនឹងប្រព័ន្ធអេកូឡូស៊ីផង និងសម្រាប់ជីវិតមនុស្ស និងជីវិតសត្វនៅលើភពផែនដីនេះផង ។ ផ្តើមចេញពីចំណុចនេះយើងទាំងអស់គ្នាបានមើលឃើញយ៉ាងច្បាស់ថា ជីវៈចម្រុះមានតម្លៃជាសេដ្ឋកិច្ច និងសង្គមកិច្ច នៅក្នុងសង្គមជាតិរបស់យើង ហេតុនេះហើយបានជាកិច្ចប្រជុំកំពូលពិភពលោកប្រព្រឹត្តធ្វើនៅប្រទេសអាហ្វ្រិកខាងត្បូងបានកំណត់នូវទស្សនទានសកលនៃផែនការយ៉ូហានេស្បឺក (Johannesburg) សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ។ គោលបំណងដ៏សំខាន់នៃផែនការនេះ គឺដើម្បីជួយកាត់បន្ថយដល់ភាពរងគ្រោះ និងការបាត់បង់នៃជីវៈចម្រុះនៅលើពិភពលោក និងភាពថយចុះជាលំដាប់នៃធនធានធម្មជាតិនៅលើភពផែនដីនៃយើង ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ជាទីមេត្រី**

៤. ភាពវិចវិលនៃប្រព័ន្ធអេកូឡូស៊ី បានបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានជាច្រើន ដូចជា ការកើនឡើងកំដៅផែនដី គ្រោះធម្មជាតិ ភាពរាំងស្ងួត ទឹកជំនន់ និងការវិនាសបាត់ពូជនៃប្រភេទសត្វនានា ដែលបង្កមហន្តរាយគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ចជាតិ សង្គម ជីវភាពរស់នៅ និងសុខមាលភាពមនុស្ស-សត្វគ្រប់ប្រភេទ ទាំងក្នុងក្របខ័ណ្ឌជាតិ សង្គម និងពិភពលោក ។ ដោយមើលឃើញ និងស្វែងយល់នូវវិនាសកម្មដ៏ធំធេងនេះហើយ ទើបរាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយយុទ្ធសាស្ត្រ

ចតុកោណដំណាក់កាលទី២ ដែលក្នុងនោះមានកាលើកស្ទួយវិស័យបរិស្ថាន ការអភិរក្ស និងគ្រប់គ្រង ប្រើប្រាស់ធនធានជីវៈចម្រុះប្រកបដោយនិរន្តរ៍ភាព សំដៅលើកកម្ពស់ការចូលរួមអនុវត្តន៍គោលនយោ-បាយ យុទ្ធសាស្ត្រអភិវឌ្ឍសហសវត្សសកល លើការអភិវឌ្ឍប្រកបដោយចិរភាព ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

៥. ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានយកចិត្តទុកដាក់ លើកទឹកចិត្ត និងជំរុញឱ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធទាំងអស់ ចាប់តាំងពីថ្នាក់មូលដ្ឋាន រហូតដល់ថ្នាក់ដឹកនាំ អ្នកវិនិយោគ និងដៃគូអភិវឌ្ឍ ដើម្បីរួមគ្នាថែរក្សាការពារជីវៈចម្រុះដើម្បីជីវិតរបស់យើង និងអនាគតមនុស្សជំនាន់ក្រោយ ។ សកម្មភាព លើកកម្ពស់ការយល់ដឹងឱ្យបានទូលំទូលាយ និងសារៈប្រយោជន៍នៃធនធានជីវៈចម្រុះ គឺជាអាទិភាពមួយក្នុងចំណោមអាទិភាពនានារបស់រាជរដ្ឋាភិបាល សំដៅជំរុញដល់ការចូលរួមចំណែកកាត់បន្ថយនូវការថយចុះនៃចំនួនជីវៈចម្រុះដែលបានកំណត់នៅក្នុងគោលដៅឆ្នាំ២០១០ របស់កិច្ចប្រជុំកំពូលនៃបណ្តាសមាជិកអនុសញ្ញាសហប្រជាជាតិលើកទី៦នៅទីក្រុងហាហ៊្គី (Hague) ប្រទេសហូឡង់ ។ ក្រៅពីនេះរាជរដ្ឋាភិបាលក៏បាន និងកំពុងអនុវត្តយុទ្ធសាស្ត្រ **ឈ្នះ~ ឈ្នះ** ដោយជំរុញលើកទឹកចិត្តឱ្យមានការចូលរួមពីសហគមន៍មូលដ្ឋាន ក្នុងការអភិរក្ស និងប្រើប្រាស់ធនធានជីវៈចម្រុះប្រកបដោយនិរន្តរ៍ភាព ស្របតាមពាក្យស្លោក "មនុស្ស និងធម្មជាតិ រស់នៅជាមួយគ្នា"

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ជាទីមេត្រី**

៦. គោលបំណងសំខាន់ ទិវាឆ្នាំអន្តរជាតិ នៃជីវៈចម្រុះ នាថ្ងៃនេះ គឺជាវេទិកាសេរី និងសាធារណៈ សម្រាប់ផ្សព្វផ្សាយដល់សាធារណៈជនគ្រប់ស្រទាប់វណ្ណៈ មន្ត្រីរាជការ អ្នកវិនិយោគ ដៃគូអភិវឌ្ឍ និងថ្នាក់ដឹកនាំគ្រប់ស្ថាប័ន និងគ្រឹះស្ថាន អំពីសារៈសំខាន់នៃជីវៈចម្រុះ ចំពោះមនុស្សជាតិ សេដ្ឋកិច្ចជាតិ និងជីវភាពរស់នៅរបស់ប្រជាជន ព្រមទាំងជំរុញ និងពង្រឹងឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នានៃបណ្តាប្រទេសជាហត្ថលេខីក្នុងអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ ដើម្បីប្តេជ្ញាក្នុងការសម្រេចឱ្យបានចំណុចគោលដៅឆ្នាំ ២០១០ និងរៀបចំទិសដៅក្រោយឆ្នាំ ២០១០ ឱ្យមានប្រសិទ្ធភាព ។ ដូច្នេះ ខ្ញុំសង្ឃឹមថា ទិវាឆ្នាំអន្តរជាតិ នៃជីវៈចម្រុះ ដែលប្រារព្ធធ្វើនៅលើទឹកដីអង្គរនេះ នឹងផ្តល់នូវវិភាគទានដ៏ថ្លៃថ្លា និងជាកម្លាំងចលកមួយ ដើម្បីរួបរួមគ្នារៀបចំយុទ្ធសាស្ត្រ និងសកម្មភាពនានា សំដៅកាត់បន្ថយ និងបញ្ឈប់រាល់សកម្មភាពដែលធ្វើឱ្យប៉ះពាល់ និងបាត់បង់ធនធានជីវៈចម្រុះ ក្រោយឆ្នាំ ២០១០ ទាំងនៅក្នុងថ្នាក់ជាតិ ថ្នាក់តំបន់ និងសកលលោក ។

៧. ជាថ្មីម្តងទៀត តាងនាមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា

ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ទាំងអស់ដែលបានលះបង់ពេលវេលាដ៏មានតម្លៃមកចូលរួមក្នុងទិវាឆ្នាំអន្តរជាតិ នៃជីវៈចម្រុះនាថ្ងៃនេះ ។ ខ្ញុំករុណា សូមប្រគេនពរព្រះតេជគុណគ្រប់ព្រះអង្គ និងជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ទាំងអស់ សូមជួបប្រទះតែនឹងសេចក្តីសុខគ្រប់ប្រការ ។

**សូមអរគុណ**